**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ : ២៨៨ សហវ.ប្រក.ស

រាជធានីភ្នំពេញ,ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០០២

# ប្រកាស
## ស្តីពី
## ការបែងចែកផលដែលបានមកពីប្រតិបត្តិការបង្ក្រាបអំពើរត់គេចពន្ធ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នរ / រកម / ០១.៩៩ / ០១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៩
- បានឃើញក្រឹត្យលេខ ៥៧ ក្រ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ១៩៨៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពន្ធលើទំនិញនាំចេញ និងនាំចូល
- បានឃើញ លិខិតបញ្ជាលេខ ០២ បប ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ
- បានឃើញ ប្រកាសលេខ ០០៩ កហវ ចុះថ្ងៃទី០៦ ខែ មេសា ឆ្នាំ១៩៩៣ របស់ក្រសួងហិរញ្ញវត្ថុ ស្តីពីការណែនាំអនុវត្តកិច្ចការផ្តល់ ការបែងចែកប្រាក់រង្វាន់
- យោងតាមសំណូមពរការងារចាំបាច់ក្នុងការបង្កើនប្រសិទ្ធភាពនៃការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ

## សំរេច

**ប្រការ ១ :** ត្រូវបានកំណត់ជាផលដែលបានមកពីប្រតិបត្តិការបង្ក្រាបអំពើរត់គេចពន្ធ បណ្តាប្រភពចំណូលណាមួយ ដែលបានមកពីប្រភពដូចខាងក្រោម ៖

១- ទឹកប្រាក់ពន្ធ អាករ ពិន័យ និងកំរៃទានា ដែលជាផលបង្ក្រាបអំពើរត់គេចពន្ធ ដែលទទួលបានក្រោយពេលមានការសំរេចវិនិច្ឆ័យពីស្ថាប័នមានសមត្ថកិច្ចលើទំនិញល្មើសទាំងនោះ ។

២- ទឹកប្រាក់ដែលបានមកពីការលក់ឡាយឡុងទំនិញ ឬ មធ្យោបាយល្មើស ដែលត្រូវរឹបអូសស្របតាមច្បាប់ជាធរមានឬដែលជនល្មើសបានប្រគល់ដោយស្ម័គ្រចិត្តនូវទំនិញឬមធ្យោបាយល្មើសនោះជូនរដ្ឋ។

**ប្រការ ២** : ទឹកប្រាក់នៃផលដែលបានមកពីប្រតិបត្តិការបង្ក្រាបអំពើរត់គេចពន្ធ ត្រូវបានកំណត់បែងចែកជាបណ្តោះអាសន្នដូចខាងក្រោម ៖

១- ៦០ ភាគរយ នៃផលសរុប ត្រូវបង់ចូលថវិការដ្ឋ ។

២- ៣០ ភាគរយ នៃផលសរុប ជាប្រាក់រង្វាន់លើកទឹកចិត្តដល់បុគ្គលនានាដែលមានស្នាដៃក្នុងការចូលរួមប្រតិបត្តិការបង្ក្រាបអំពើរត់គេចពន្ធ ។

៣- ១០ ភាគរយ នៃផលសរុប ត្រូវបង់ចូលបេឡាមូលនិធិបង្ក្រាបអំពើរត់គេចពន្ធ ។

**ប្រការ ៣** ត្រូវបានជូនរង្វាន់លើកទឹកចិត្តដល់បុគ្គលទាំងឡាយណាដែលបានចូលរួមក្នុងការផ្តល់ដំណឹង ការតាមដានស្រាវជ្រាវត្រួតពិនិត្យ និងបង្ក្រាបអំពើរត់គេចពន្ធដែលនាំឱ្យរកឃើញ និងបង្ក្រាបបាននូវបទល្មើសគយតាមគ្រប់រូបភាព ។

**ប្រការ ៤** : ទឹកប្រាក់រង្វាន់លើកទឹកចិត្តដូចមានចែងក្នុងចំណុច ០២ ប្រការ ០២ ខាងលើនេះ ត្រូវបានបែងចែកដូចខាងក្រោម ៖

១- ចំនួនប្រាក់ ៥០ ភាគរយ នៃប្រាក់រង្វាន់សរុប សំរាប់ផ្តល់ចំពោះបុគ្គលដែលបានចូលរួមក្នុងប្រតិបត្តិការបង្ក្រាបអំពើរត់គេចពន្ធដោយផ្ទាល់ ។

២- ចំនួនប្រាក់ ១០ ភាគរយ នៃប្រាក់រង្វាន់សរុប សំរាប់ផ្តល់ចំពោះអ្នកផ្តល់ពត៌មានដែលនាំឱ្យរកឃើញនូវបទល្មើសនេះ ។ ក្នុងករណីពុំមានអ្នកផ្តល់ពត៌មាន ទឹកប្រាក់នេះត្រូវបន្ថែមជូនជាប្រាក់រង្វាន់ ចំពោះបុគ្គលដែលបានចូលរួមដោយផ្ទាល់ក្នុងប្រតិបត្តិការបង្ក្រាបអំពើរត់គេចពន្ធដូចមានចែងក្នុងចំណុច ០១ នៃប្រការនេះ ។

៣- ចំនួនប្រាក់ ១០ ភាគរយ នៃប្រាក់រង្វាន់សរុបសំរាប់ប្រើប្រាស់ដើម្បីផ្តល់ជូនដល់បុគ្គលដែលបានចូលរួមធ្វើអន្តរាគមន៍ដោយប្រយោលផ្សេងទៀត ។

៤- ចំនួនប្រាក់ ១៥ ភាគរយ នៃទឹកប្រាក់រង្វាន់ដែលនៅសល់ ត្រូវបែងចែកដូចតទៅ ៖

- ០៥ ភាគរយ សំរាប់ឧបត្ថម្ភកិច្ចដំណើរការទីស្នាក់ការគយនិងរដ្ឋាករដែលមានស្នាដៃ ។
- ០៥ ភាគរយ សំរាប់ឧបត្ថម្ភកិច្ចដំណើរការការិយាល័យ សាខាគយនិងរដ្ឋាករ ដែលគ្រប់គ្រងទីស្នាក់ការគយនិងរដ្ឋាករ ។
- ០៥ ភាគរយ សំរាប់ឧបត្ថម្ភកិច្ចដំណើរការរបស់ទីចាត់ការគយនិងរដ្ឋាករទាំងមូល ។

ក្នុងករណីដែលទំនិញល្មើសនោះ ត្រូវបង្ក្រាបបានដោយការិយាល័យ ឬ សាខាគយនិងរដ្ឋាករ ប្រាក់រង្វាន់ ១៥ ភាគរយ ដែលចែងក្នុងចំណុច ០៤ នៃប្រការនេះ ត្រូវបែងចែកដូចខាងក្រោម៖

- ០៥ ភាគរយ សំរាប់ឧបត្ថម្ភកិច្ចដំណើរការរបស់ការិយាល័យ សាខាគយនិងរដ្ឋាករសាមី ដែលមានស្នាដៃ ។
- ១០ ភាគរយ សំរាប់ឧបត្ថម្ភកិច្ចដំណើរការរបស់ទីចាត់ការគយនិងរដ្ឋាករទាំងមូល ។

៥- ចំនួនប្រាក់ ១៥ ភាគរយ នៃប្រាក់រង្វាន់សរុប សំរាប់ឧបត្ថម្ភកិច្ច[illegible]ភាព ឬ/និងអាជ្ញាធរដែនដីដែលបានចូលរួមបង្កើតស្នាដៃក្នុងប្រតិបត្តិការ[illegible] ។

ក្នុងករណីដែលការរកឃើញបទល្មើសច្បាប់គយ ពុំមានការចូល[illegible]

ឬពុំមានអន្តរាគមន៍ពីអង្គភាព ឬ អាជ្ញាធរដែនដីនោះទេ ទឹកប្រាក់រង្វាន់ ដែលបែងចែកក្នុងចំណុច ០៤ ឬចំណុច ០៥ នៃប្រការនេះត្រូវបង់ចូលបេឡាមូលនិធិបង្ក្រាបអំពើរត់គេចពន្ធ ។ ក្នុងករណីទឹកប្រាក់ដែលត្រូវផ្តល់រង្វាន់សរុបលើសពី ១០០ លានរៀល ការបែងចែកត្រូវមានការសំរេចជាមុនពីរាជរដ្ឋាភិបាល ។

**ប្រការ ៥ :** មូលនិធិបង្ក្រាបអំពើរត់គេចពន្ធដែលមានចែងក្នុងចំណុច ០៣ នៃប្រការ០២ ខាងលើត្រូវគ្រប់គ្រងដោយទីចាត់ការគយនិងរដ្ឋាករ សំរាប់បំរើឱ្យការចំណាយបណ្តោះអាសន្នមុនក្នុងករណីចាំបាច់ រួចទូទាត់បញ្ចូលវិញក្នុងប្រតិបត្តិការនិមួយៗ និងសំរាប់ទូទាត់ចំណាយក្នុងប្រតិបត្តិការណាដែលពុំទទួលបានផល ឬ ទទួលបានផលពុំគ្រប់គ្រាន់សំរាប់បំរើការចំណាយជាក់ស្តែង ។ ទឹកប្រាក់មូលនិធិបង្ក្រាបអំពើរត់គេចពន្ធ ត្រូវប្រើប្រាស់តែលើការចំណាយចាំបាច់ និងបន្ទាន់នានារួមមាន ការហូបចុក ការស្នាក់នៅ ការទិញប្រេងឥន្ធនៈសំរាប់មធ្យោបាយដឹកជញ្ជូន និងការជួលមធ្យោបាយដឹកជញ្ជូនបំរើឱ្យប្រតិបត្តិការក្នុងករណីចាំបាច់ប៉ុណ្ណោះ ។ ការចំណាយតាមតំរូវការផ្សេងទៀតខុសពីមុខសញ្ញាទាំងនេះ ត្រូវមានការឯកភាពជាមុនពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ ៦ :** បណ្តាការចំណាយនានាពាក់ព័ន្ធនឹងការថែរក្សា សន្និធិ លើកដាក់ ផ្ទេរផ្ទុរ និងការដឹកជញ្ជូនទំនិញឬមធ្យោបាយល្មើសជាបន្ទុករបស់ម្ចាស់ ឬ តំណាងម្ចាស់ទំនិញឬមធ្យោបាយល្មើស ។

**ប្រការ ៧ :** សំរាប់ប្រតិបត្តិការស្រាវជ្រាវបង្ក្រាបអំពើរត់គេចពន្ធមានលក្ខណៈលំបាកស្មុគ្រស្មាញខ្លាំង ដែលត្រូវចំណាយកំលាំងពលកម្មធនធានសំភារៈច្រើន និងរយៈពេលយូរផងនោះ ទីចាត់ការគយនិងរដ្ឋាករ ត្រូវធ្វើសំណើអមដោយរបាយការណ៍ច្បាស់លាស់ ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីសុំការពិនិត្យ និងសំរេចជូនប្រាក់រង្វាន់ក្នុងកំរិតខ្ពស់សមរម្យមួយ ជាករណីពិសេស ។

**ប្រការ ៨ :** ប្រកាសទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ នឹងត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៩ :** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា នាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានព្រមទាំង អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី ( ដើម្បីជូនជាពត៌មាន )
- ទីចាត់ការគយនិងរដ្ឋាករ
- សភាពាណិជ្ជកម្ម ( ដើម្បីសហការផ្សព្វផ្សាយនិងអនុវត្ត )
- ឯកសារ-កាលប្បវត្តិ